**សកម្មភាព** ៖ ប្រៀបធៀប ធ្ងន់ និងស្រាល

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**បុរេគណិត**

រង្វាស់រង្វាល់ (បញ្ញត្តិស្តីពីរង្វាស់រង្វាល់)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(បុរេគណិត)** ប្រាប់បានពីបញ្ញត្តិ ធ្ងន់ និងស្រាល

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកពូកែអី? "

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០នាទី

**ឧបករណ៍** ៖ សម្រាប់ជញ្ជីងគឺទំពក់ព្យួរអាវមានគន្លាក់ (បើមិនមានគន្លាក់ ចូរបិទខ្សែនៅលើទំពក់) ខ្សែ ឬអំបោះ ប្រដាប់ចោះ ឬ ម្ជុលសម្រាប់ចោះខ្សែតាមកំប៉ុង កំប៉ុងក្រដាសដូចគ្នាពីរ កន្ត្រៃ ស្កុត។

**ការរៀបចំ** ៖ ប្រមូលវត្ថុសម្រាប់ថ្លឹងដូចជា អំបិល សណ្តែកដែលមានទំហំខុសគ្នា ម្សៅ គម្របដបក្រដាស។

-រៀបចំវត្ថុសម្រាប់ថ្លឹង ដែលឱ្យកុមារៗយកមកពីផ្ទះ។

-វត្ថុខ្លះអាចដាក់ក្នុងកំប៉ុងក្រដាសតូចបាន ដោយពុំចាំបាច់ដាក់ឱ្យពេញពេកទេ។

**សូមអនុវត្តតាមជំហានទាំងនេះ ដើម្បីធ្វើជញ្ជីង៖**



- ចូរវាស់នឹងកាត់ខ្សែពីរដែលមានប្រវែង ៦០សម។
- ចូរដៅចំណុចពីរ នៅខាងក្រោមមាត់កំប៉ុងខាងក្រៅ ធានាថាចំណុចទាំងពីរមានទីតាំងផ្ទុយគ្នា។
- ចោះប្រហោងត្រង់ចំណុចដៅនីមួយៗ ហើយដាក់ខ្សែចូល។ អ្នកអាចដេរខ្សែនៅលើចំណុចដៅកំប៉ុង។
- ចូរព្យួរជញ្ជីងនៅទីតាំងណាដែលកុមារៗអាចឈោងដល់។
- ចូរចងខ្សែកំប៉ុងនីមួយៗ ហើយដាក់វាលើគន្លាក់ទំពក់។
- ប្រសិនបើទំពក់មិនមាន/គន្លាក់ បិទស្កុតខ្សែនៅលើទំពក់ដោយដាក់ឱ្យមានចម្ងាយស្មើគ្នាពីខាងចុង។ ខ្សែគួរតែអាចគាំទ្រកំប៉ុងបាន ដូចដៃធុង។
- ចូរពិនិត្យកំប៉ុងឱ្យស្មើគ្នាមុនប្រើប្រាស់។

**សេចក្តីណែនាំ៖**

1. និយាយ៖ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**ប្រៀបធៀប ធ្ងន់ និងស្រាល** ជាមួយកូនៗទាំងអស់គ្នា។
2. និយាយអំពីលោកគ្រូសុខ ដែលមានកម្លាំងខ្លាំង ហើយមនុស្សខ្លាំងអាចលើកវត្ថុធ្ងន់ៗបាន។
3. សួរក្មេងៗ៖ តើកូនៗស្គាល់ពាក្យ "ធ្ងន់" ដែរឬទេ? បាទ/ចាស ស្គាល់។
   តើពាក្យផ្ទុយពីពាក្យធ្ងន់ជាពាក្យអ្វី? បាទ/ចាស ស្រាល។
4. ចូរឱ្យក្មេងៗផ្តល់ឧទាហរណ៍មួយចំនួន អំពីវត្ថុធ្ងន់ និងវត្ថុស្រាល។
   សូមកូនៗឧទាហរណ៍វត្ថុមួយណាដែលធ្ងន់ឱ្យអ្នកគ្រូម្នាក់មួយ?
   មានដូចជាកំប៉ុងដែក កៅអីឈើ ដែកគឺប ត្រី អង្ករ ...។
   សូមកូនៗឧទាហរណ៍វត្ថុមួយណាដែលស្រាលឱ្យអ្នកគ្រូម្នាក់មួយ?
   មានដូចជាក្រដាស ថង់ កៅអីជ័រ ...។
5. ចូរឱ្យក្មេងៗផ្តល់ឧទាហរណ៍ប្រៀបធៀបមួយចំនួនអំពីវត្ថុធ្ងន់ជាង និងវត្ថុស្រាលជាង។
   ឧទាហរណ៍៖ ថង់នេះស្រាលជាងក្រដាសនេះ។
   កៅអីដែកនេះធ្ងន់ជាងកៅអីជ័រនេះ។
6. ចាប់ផ្តើមលេងដោយឱ្យក្មេងៗជ្រើសរើសដាក់វត្ថុសម្រាប់ថ្លឹងទៅក្នុងកំប៉ុងរបស់ជញ្ជីង។
7. ឱ្យក្មេងម្នាក់ជ្រើសរើសវត្ថុមួយដែលស្រាលដាក់ចូលទៅ។
8. បន្ទាប់មកឱ្យក្មេងម្នាក់ទៀតជ្រើសរើសវត្ថុដែលធ្ងន់ចូលទៅទៀត។
9. ចូរពិភាក្សាថា៖តើវត្ថុមួយណាដែលកូនៗគិតថាស្រាល?
   តើវត្ថុមួយណាដែលកូនៗគិតថាធ្ងន់? ហេតុអ្វី? ឆ្លើយប្រាប់តាមស្ថានភាពវត្ថុ។
10. ឱ្យក្មេងម្នាក់ជ្រើសរើសវត្ថុមួយដែលស្រាលជាងដាក់ចូលទៅ។
11. បន្ទាប់មកឱ្យក្មេងម្នាក់ទៀតជ្រើសរើសវត្ថុដែលធ្ងន់ជាងចូលទៅទៀត។
12. តើវត្ថុមួយណាដែលកូនៗគិតថាស្រាលជាង?
    តើវត្ថុមួយណាដែលកូនៗគិតថាធ្ងន់ជាង? ហេតុអ្វី? ឆ្លើយប្រាប់តាមស្ថានភាពវត្ថុ។
13. ចូរអនុវត្តជំហានទាំងនេះម្តងទៀតសម្រាប់វត្ថុផ្សេងៗដែលអ្នកបានប្រមូល។

**បម្រែបម្រួល៖** ចូរឱ្យក្មេងៗថ្លឹងវត្ថុផ្សេងៗនៅក្នុងថ្នាក់រៀន និងប្រៀបធៀបទម្ងន់របស់វត្ថុទាំងនោះ ដំបូងទាយសិនថាវត្ថុណាធ្ងន់បំផុត ហើយវត្ថុណាស្រាលបំផុត។